# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១៣២ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្មនិងអង្គភាពលទ្ធកម្ម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងការតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នសរ/កម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៥ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការកែសម្រួលមាត្រា៥០ មាត្រា៥១ មាត្រា៥២ និងមាត្រា៥៣ នៃអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៨៩ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះ កំណត់អំពីក្របខ័ណ្ឌគតិយុត្តសម្រាប់ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្មនិងអង្គភាពលទ្ធកម្ម នៅស្ថាប័នអនុវត្តលទ្ធកម្ម ក្នុងគោលបំណងដើម្បីធានាឱ្យការដឹកនាំនិងការអនុវត្តលទ្ធកម្មសាធារណៈ សម្រាប់ការទិញ ការសាងសង់ ការជួសជុល ការជួលសេវាកម្ម និងការជួលសេវាទីប្រឹក្សា ប្រព្រឹត្តទៅដោយរលូន ប្រកបដោយតម្លាភាព គណនេយ្យភាព សុចរិតភាព ការប្រកួតប្រជែង ភាពយុត្តិធម៌ ប្រសិទ្ធភាព សក្តិសិទ្ធិភាព ចីរភាព គុណភាព ការសន្សំសំចៃ និងភាពទាន់ពេល។

**មាត្រា២ .-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះស្ថាប័នអនុវត្តលទ្ធកម្ម ដែលរួមមាន ក្រសួង ស្ថាប័ន អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត ដែលអនុវត្តលទ្ធកម្មសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣ .-**

និយមន័យនៃបច្ចេកសព្ទដែលប្រើប្រាស់ក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់ដោយសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៥ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣។

## ជំពូកទី២
## គណៈកម្មាធិការលទ្ធកម្ម

**មាត្រា៤ .-**

ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវបង្កើតគណៈកម្មាធិការលទ្ធកម្មមួយ និងអង្គភាពលទ្ធកម្មមួយ សម្រាប់ដឹកនាំនិងអនុវត្តលទ្ធកម្មសាធារណៈឱ្យស្របតាមគោលការណ៍ វិធាន វិធីសាស្ត្រ និងនីតិវិធីដែលកំណត់ដោយច្បាប់ស្តីពីលទ្ធកម្មសាធារណៈនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀតជាធរមាន។

ចំពោះស្ថាប័នអនុវត្តលទ្ធកម្មដែលជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ ត្រូវបង្កើតក្រុមលទ្ធកម្ម ឬគណៈកម្មាធិការលទ្ធកម្មនិងអង្គភាពលទ្ធកម្ម ទៅតាមលក្ខណវិនិច្ឆ័យ ដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៥ .-**

ការបង្កើតគណៈកម្មាធិការលទ្ធកម្មរបស់ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវធ្វើឡើងតាមការសម្រេចរបស់ប្រធានស្ថាប័នអនុវត្តលទ្ធកម្ម។ ចំពោះការបង្កើតគណៈកម្មាធិការលទ្ធកម្មរបស់សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត ត្រូវធ្វើឡើងដោយប្រធានអង្គភាពប្រតិបត្តិ ដោយមានការអនុម័តយល់ព្រមជាមុនពីក្រុមប្រឹក្សាភិបាល។

**មាត្រា៦ ._**

គណៈកម្មាធិការលទ្ធកម្ម មានសមាសភាពដូចខាងក្រោម៖

- ថ្នាក់ដឹកនាំបន្ទាប់ តាមការប្រគល់សិទ្ធិពីប្រធានស្ថាប័នអនុវត្តលទ្ធកម្ម ប្រធាន
- ថ្នាក់ដឹកនាំនៃស្ថាប័នអនុវត្តលទ្ធកម្ម ១ ឬ ២រូប អនុប្រធាន
- ប្រធាន និង/ឬអនុប្រធាន នៃអង្គភាពទទួលបន្ទុកកិច្ចការហិរញ្ញវត្ថុដែលអាចជា អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន នាយកដ្ឋាន ឬការិយាល័យ ១ ឬ២រូប សមាជិក
- ប្រធានអង្គភាពលទ្ធកម្ម លេខាធិការ។

គណៈកម្មាធិការលទ្ធកម្ម អាចមានតំណាងអង្គភាពបច្ចេកទេសពាក់ព័ន្ធនឹងមុខសញ្ញាលទ្ធកម្ម ជាសមាជិកចំពោះកិច្ច អាស្រ័យទៅតាមគម្រោងនីមួយៗ។

សមាសភាពជាក់ស្តែងនៃគណៈកម្មាធិការលទ្ធកម្ម ត្រូវជ្រើសតាំងតាមការសម្រេចរបស់ប្រធានស្ថាប័នអនុវត្តលទ្ធកម្ម។

**មាត្រា៧ ._**

ប្រធានស្ថាប័នអនុវត្តលទ្ធកម្ម អាចអញ្ជើញមន្ត្រីជំនាញក្នុងស្ថាប័នរបស់ខ្លួន ឬមន្ត្រីជំនាញពីស្ថាប័នផ្សេងក្នុងករណីពុំមានមន្ត្រីជំនាញក្នុងស្ថាប័នរបស់ខ្លួន ដើម្បីផ្តល់យោបល់ជំនាញពាក់ព័ន្ធនឹងគម្រោង។

**មាត្រា៨ ._**

សមាសភាពគណៈកម្មាធិការលទ្ធកម្មទាំងអស់ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន កិច្ចប្រជុំអាចប្រព្រឹត្តទៅតាមការអញ្ជើញរបស់អនុប្រធាន តាមការប្រគល់សិទ្ធិរបស់ប្រធាន។

**មាត្រា៩ ._**

គណៈកម្មាធិការលទ្ធកម្ម មានភារកិច្ចជាសារវន្ត ដូចខាងក្រោម៖

- ពិនិត្យនិងសម្រេចលើសេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំ ដែលរៀបចំដោយអង្គភាពលទ្ធកម្ម មុននឹងដាក់ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពិនិត្យនិងអនុម័ត
- ត្រួតពិនិត្យនិងជំរុញឱ្យអង្គភាពលទ្ធកម្មអនុវត្តតាមផែនការលទ្ធកម្មឱ្យបានត្រឹមត្រូវ
- ពិនិត្យ វាយតម្លៃ និងកំណត់បុរេលក្ខណសម្បត្តិ ចំពោះកិច្ចលទ្ធកម្មដែលមានលក្ខណៈបច្ចេកទេសស្មុគស្មាញ
- ពិនិត្យឡើងវិញលើទំហំទឹកប្រាក់នៃកញ្ចប់លទ្ធកម្មនីមួយៗ ដោយផ្ទៀងផ្ទាត់ជាមួយផែនការលទ្ធកម្មមុននឹងចាប់ផ្តើមដំណើរការលទ្ធកម្ម
- ពិនិត្យនិងសម្រេចលើឯកសារដេញថ្លៃ
- ប្រជុំបើកសំណុំឯកសារស្នើដេញថ្លៃ ពិគ្រោះថ្លៃ ស្ទង់តម្លៃ ឬចរចាថ្លៃ
- ប្រជុំពិនិត្យនិងវាយតម្លៃសំណុំឯកសារស្នើដេញថ្លៃ



9

- ត្រួតពិនិត្យនិងវាយតម្លៃលើលក្ខណសម្បត្តិតាមក្រោយរបស់អ្នកដេញថ្លៃនាំមុខ ដើម្បីដាក់ជូនប្រធានស្ថាប័នអនុវត្តលទ្ធកម្មអនុម័តលើការសម្រេចប្រគល់កិច្ចសន្យា
- ជូនដំណឹងស្តីពីការសម្រេចប្រគល់កិច្ចសន្យាទៅអ្នកដេញថ្លៃឈ្នះ និងចម្លងជូនទៅគ្រប់អ្នកដេញថ្លៃចាញ់
- ឆ្លើយតបជាលាយលក្ខណ៍អក្សរទៅអ្នកដេញថ្លៃចាញ់ ក្នុងករណីមានការស្នើសុំបំភ្លឺអំពីមូលហេតុនៃបរាជ័យក្នុងការដេញថ្លៃរបស់ខ្លួន
- បញ្ជូនឯកសារដេញថ្លៃ សំណុំឯកសារស្នើដេញថ្លៃ និងការស្នើសុំជ្រើសរើសនិងប្រគល់កិច្ចសន្យាទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យនិងសម្រេច ចំពោះគម្រោងលទ្ធកម្មដែលត្រូវពិនិត្យនិងសម្រេចដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ផ្សព្វផ្សាយលទ្ធផលនៃការដេញថ្លៃជាសាធារណៈ
- គ្រប់គ្រង និងតាមដានការអនុវត្តកិច្ចសន្យា
- អញ្ជើញតំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចូលរួមសង្កេតការណ៍ នៅដំណាក់កាលបើកសំណុំឯកសារស្នើដេញថ្លៃ ប្រជុំចរចាថ្លៃ និងការប្រគល់ ទទួល ចំពោះគម្រោងលទ្ធកម្មដែលត្រូវពិនិត្យនិងសម្រេចដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ពិនិត្យនិងដោះស្រាយបណ្តឹងតវ៉ាពាក់ព័ន្ធនឹងកិច្ចលទ្ធកម្ម
- ពិនិត្យរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្មប្រចាំត្រីមាស ឆមាស និងឆ្នាំ មុននឹងដាក់ជូនប្រធានស្ថាប័នអនុវត្តលទ្ធកម្មចុះហត្ថលេខា ដើម្បីផ្ញើជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៣
## អង្គភាពលទ្ធកម្ម

### មាត្រា១០.-

ការបង្កើតអង្គភាពលទ្ធកម្មរបស់ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវធ្វើឡើងតាមការសម្រេចរបស់ប្រធានស្ថាប័នអនុវត្តលទ្ធកម្ម។ ចំពោះការបង្កើតអង្គភាពលទ្ធកម្មរបស់សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពស្វយ័តភាពហិរញ្ញវត្ថុដទៃទៀត ត្រូវធ្វើឡើងដោយប្រធានអង្គភាពប្រតិបត្តិ ដោយមានការអនុម័តយល់ព្រមជាមុនពីក្រុមប្រឹក្សាភិបាល។

អង្គភាពលទ្ធកម្ម ត្រូវមានរចនាសម្ព័ន្ធច្បាស់លាស់និងមានមន្ត្រីមានសមត្ថភាពជំនាញផ្នែកលទ្ធកម្មសាធារណៈគ្រប់គ្រាន់ ព្រមទាំងមានសិទ្ធិអំណាចសមស្រប ដើម្បីទទួលខុសត្រូវលើការអនុវត្តលទ្ធកម្មសាធារណៈ។

អង្គភាពលទ្ធកម្ម មានរចនាសម្ព័ន្ធស្ថិតក្រោមប្រធានស្ថាប័នអនុវត្តលទ្ធកម្មផ្ទាល់ និងជាសេនាធិការឱ្យគណៈកម្មាធិការលទ្ធកម្ម។

**មាត្រា១១ ._**

អង្គភាពលទ្ធកម្ម ត្រូវដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានចំនួនមួយរូបជាជំនួយការ។ ប្រធានអង្គភាពលទ្ធកម្ម មិនត្រូវមានតួនាទីនិងភារកិច្ចពាក់ព័ន្ធនឹងកិច្ចការហិរញ្ញវត្ថុផ្សេងទៀតក្នុងស្ថាប័នរបស់ខ្លួនឡើយ។

ប្រាក់បំណាច់មុខងារប្រធាន អនុប្រធានអង្គភាពលទ្ធកម្ម និងមន្ត្រីជំនាញលទ្ធកម្ម ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា១២ ._**

ប្រធាននិងអនុប្រធានអង្គភាពលទ្ធកម្ម ត្រូវមានលក្ខណសម្បត្តិ ដូចខាងក្រោម៖

- មានកម្រិតវប្បធម៌ចាប់ពីបរិញ្ញាបត្រផ្នែកសេដ្ឋកិច្ច ឬផ្នែកហិរញ្ញវត្ថុ
- មានបទពិសោធន៍ការងារផ្នែកសេដ្ឋកិច្ច ឬផ្នែកហិរញ្ញវត្ថុយ៉ាងតិច ៣(បី)ឆ្នាំ និង
- ធ្លាប់បានឆ្លងកាត់វគ្គបណ្តុះបណ្តាលផ្នែកលទ្ធកម្មសាធារណៈ ដោយមានវិញ្ញាបនបត្របញ្ជាក់ពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១៣ ._**

អង្គភាពលទ្ធកម្ម បំពេញមុខងារជាសេនាធិការឱ្យគណៈកម្មាធិការលទ្ធកម្ម ដោយមានភារកិច្ចជាសារវន្តដូចខាងក្រោម៖

- រៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ និង/ឬផែនការលទ្ធកម្មកែតម្រូវក្នុងករណីចាំបាច់
- រៀបចំឯកសារដេញថ្លៃសម្រាប់ប្រភេទលទ្ធកម្មនីមួយៗ ផ្អែកតាមគំរូឯកសារដេញថ្លៃដែលកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- រៀបចំ ផ្សព្វផ្សាយ និងចម្លងជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនូវសេចក្តីជូនដំណឹងអំពីការដេញថ្លៃ
- លក់ ឬផ្តល់ឯកសារដេញថ្លៃជូនអ្នកមានបំណងចូលរួមដេញថ្លៃ
- ទទួលសំណុំឯកសារស្នើដេញថ្លៃ និងបកស្រាយបំភ្លឺចំពោះអ្នកដេញថ្លៃ ក្នុងករណីមានសំណួរពាក់ព័ន្ធនឹងការដេញថ្លៃ
- រៀបចំនិងគ្រប់គ្រងសំណុំឯកសារស្នើដេញថ្លៃ រួមទាំងឯកសារពាក់ព័ន្ធដែលបានទទួល ឱ្យបានត្រឹមត្រូវនិងមានសុវត្ថិភាព មុនពេលបើកសំណុំឯកសារស្នើដេញថ្លៃ
- ចាត់ចែងនិងរៀបចំទីកន្លែងសម្រាប់បើកសំណុំឯកសារស្នើដេញថ្លៃ
- រៀបចំបើកសំណុំឯកសារស្នើដេញថ្លៃជាសាធារណៈ ដោយមានការត្រួតពិនិត្យពីគណៈកម្មាធិការលទ្ធកម្ម
- រៀបចំរបាយការណ៍ឬកំណត់ហេតុស្តីពីការបើកសំណុំឯកសារស្នើដេញថ្លៃ ពិគ្រោះថ្លៃ ស្វង់តម្លៃ ឬចរចាថ្លៃ
- សម្របសម្រួលការវាយតម្លៃលើលក្ខណៈបច្ចេកទេសនៃសំណុំឯកសារស្នើដេញថ្លៃ
- ឆ្លើយតបចំពោះសំណួរពាក់ព័ន្ធនឹងរបាយការណ៍វាយតម្លៃលើសំណុំឯកសារស្នើដេញថ្លៃ



៥

- រៀបចំលិខិតជូនដំណឹងស្ដីពីការសម្រេចប្រគល់កិច្ចសន្យា ដល់អ្នកដេញថ្លៃឈ្នះ និងចម្លងជូនគ្រប់អ្នកដេញថ្លៃចាញ់
- រៀបចំសេចក្ដីព្រាងកិច្ចសន្យាដោយអនុលោមតាមបទដ្ឋាន និងគំរូកិច្ចសន្យាដែលកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- តាមដានការអនុវត្តកិច្ចសន្យា ដោយសហការជាមួយមន្ត្រីបច្ចេកទេស និងមន្ត្រីជំនាញពាក់ព័ន្ធផ្សេងទៀត
- រៀបចំផ្សព្វផ្សាយផែនការលទ្ធកម្ម លទ្ធផលនៃការដេញថ្លៃ និងលទ្ធផលនៃបណ្ដឹងតវ៉ា
- រៀបចំរបាយការណ៍ស្ដីពីការអនុវត្តកិច្ចលទ្ធកម្មប្រចាំត្រីមាស ឆមាស និងឆ្នាំ។

## ជំពូកទី៤
## បទប្បញ្ញត្តិដោយឡែក

**មាត្រា១៤ .-**

ការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងគណៈកម្មការលទ្ធកម្មរបស់រដ្ឋបាលឃុំ សង្កាត់ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៥
## អន្តរប្បញ្ញត្តិ

**មាត្រា១៥ .-**

លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មរបស់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត ដែលត្រូវបានដាក់ឱ្យអនុវត្តដោយផ្អែកលើបទប្បញ្ញត្តិនៃអនុក្រឹត្យលេខ ១៣ អនក្រ.ប្រក ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥ ស្ដីពីនីតិវិធីនៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្មនិងអង្គភាពលទ្ធកម្ម និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងគណៈកម្មការលទ្ធកម្មរបស់រដ្ឋបាលឃុំ សង្កាត់ជាធរមាន ត្រូវបន្តសុពលភាពអនុវត្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស ស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា១៦ .-**

អនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥ ស្ដីពីនីតិវិធីនៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្មនិងអង្គភាពលទ្ធកម្ម និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។



9

**មាត្រា១៧ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ប្រធានសហគ្រាសសាធារណៈ នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ប្រធានគ្រប់អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ១២កើត ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែសីហា ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ